**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖ **សាធារណៈ**

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថា តើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ រួមទាំង [redacted] បានឬយ៉ាងណា**

---

**ដាក់ដោយ÷**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន÷**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) អនុលោមតាមវិធាន ២១ និង ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. (“វិធាន”) តាមរយៈនេះ ស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺពីសហចៅក្រមស៊ើបអង្កេតថា តើខ្លួនអាចទាក់ទងជាមួយបុគ្គលទាំងឡាយ ដូចជា សាក្សី ឬ សាក្សីសក្ដានុភូត ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅបានឬយ៉ាងណា។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះមេធាវីការពារក្ដីមានបំណងចង់ទាក់ទងជាមួយបុគ្គលទាំងឡាយ រួមទាំង[redacted] ផងដែរ។ មេធាវីការពារក្ដីយល់ឃើញថា បុគ្គលទាំងនេះអាចផ្ដល់ព័ត៌មានលម្អិតទូទៅ ទាក់ទងនឹងតំបន់ដែលពាក់ព័ន្ធជាសក្ដានុពលទៅនឹងរឿងក្ដី ០០៣។ មេធាវីការពារក្ដីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ដោយដាក់ការបកប្រែជាភាសាខ្មែរជូនតាមក្រោយ ដោយសារអង្គភាពបកប្រែភាសាមិនអាចបញ្ចប់ការបកប្រែទាន់ពេលវេលា[1]។

## I. សំណើ

១. មេធាវីការពារក្ដីមានបំណងចង់ទាក់ទងជាមួយបុគ្គលទាំងឡាយ ដូចជា សាក្សី ឬ សាក្សីសក្ដានុភូត ដើម្បីសួរថា តើពួកគាត់មានបំណងចង់ធ្វើជាអ្នកនាំផ្លូវទៅកាន់តំបន់ទាំងឡាយ ដែលពាក់ព័ន្ធជាសក្ដានុពលទៅនឹងរឿងក្ដី ០០៣ និង ផ្ដល់ព័ត៌មានលម្អិតទូទៅដែលទាក់ទងនឹងតំបន់ទាំងអស់នេះឬយ៉ាងណា។ មេធាវីការពារក្ដីក៏ស្នើសុំទាក់ទងជាមួយ[redacted]ផងដែរ ដើម្បីចុះទៅមើល[redacted] និង ប្រមូលព័ត៌មានលម្អិតទូទៅទាក់ទងនឹង[redacted] ព្រោះ[redacted]ស្ថិតនៅក្នុងអំឡុងពេលនៃ[redacted]។ កិច្ចព្រមព្រៀង[2] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.[3] និង វិធានផ្ទៃក្នុង មិនបានចែងអំពីការណែនាំគ្រប់គ្រាន់ថា តើមេធាវីការពារក្ដីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅបានឬយ៉ាងណា។ មេធាវីការពារក្ដីស្នើសុំការបញ្ជាក់បំភ្លឺពីសហចៅក្រមស៊ើបអង្កេតថា តើការទាក់ទងបែបនេះត្រូវបានអនុញ្ញាតឬយ៉ាងណា។

---

[1] *សូមមើល* សារអេឡិចត្រូនិចមកពី លោក គាំ ច័ន្ទមុនី ផ្ញើជូនមេធាវីការពារក្ដី “ឆ្លើយតប៖ សំណើសុំការបកប្រែ” ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ដែលបង្ហាញថា ការបកប្រែមិនអាចបញ្ចប់បានរហូតដល់ត្រឹមថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥។

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”)។

[3] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.”)។

២. កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុង ចង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត[4]។ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារទាំងអស់នេះ មិនកំណត់និយមន័យអំពីអ្វីទៅជា "ការស៊ើបអង្កេត" នោះទេ ហើយឯកសារទាំងអស់នេះក៏មិនផ្តល់នូវការណែនាំថា តើភាគីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ ក្នុងគោលបំណងដែលមិនមែនជាការស៊ើបអង្កេតឬយ៉ាងណាដែរ។ គ្មានបទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង ដែលហាមឃាត់យ៉ាងច្បាស់លាស់មិនឱ្យភាគីទាក់ទងជាមួយបុគ្គលទាំងឡាយ ដូចជា សាក្សី ឬ សាក្សីសក្តានុភូតនោះឡើយ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស.") និង អង្គបុរេជំនុំជម្រះបានសម្រេចថា ភាគីនានាមិនអាចធ្វើការស៊ើបសួរដោយខ្លួនឯងបានទេ ហើយមិនអាចទាក់ទងជាមួយសាក្សី ក្នុងគោលបំណងស៊ើបអង្កេតនោះបានទេ[5]។ ក.ស.ច.ស. និង អង្គបុរេជំនុំជម្រះ បានផ្តល់ការណែនាំតិចតួចថា តើភាគីអាចទាក់ទងជាមួយបុគ្គលទាំងឡាយ ក្នុងគោលបំណងផ្សេងទៀតបានដែរឬយ៉ាងណា។

---

[4] *សូមមើល* មាត្រា ៥(១) នៃកិច្ចព្រមព្រៀង៖ "មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និង ចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត"។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.៖ "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និង ម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត"។ វិធាន ៥៥ នៃវិធានផ្ទៃក្នុង៖ "១. ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ២. *សហចៅក្រមស៊ើបអង្កេត* ត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" (ការគូសបញ្ជាក់បន្ថែម)។

[5] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតមកពី ក.ស.ច.ស. ផ្ញើជូនមេធាវីការពារក្តី "កម្មវត្ថុ៖ ការឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៧ ពាក់ព័ន្ធនឹងការធ្វើកិច្ចស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ ឯកសារ A110/I ទំព័រ ២៖"មិនមានបទប្បញ្ញត្តិណាមួយដែលអនុញ្ញាតឱ្យភាគីបំពេញកិច្ចស៊ើបអង្កេតជំនួសចៅក្រមស៊ើបអង្កេត..."។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេស ចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D315/1/5 កថាខណ្ឌ ១៥៖"... ស.ច.ស. ទទួលខុសត្រូវចំពោះការដឹកនាំកិច្ចស៊ើបសួរ..."។

៣. សហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ភាគីត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបសួរបឋម[6] ដោយមិនបានកំណត់ឱ្យបានច្បាស់លាស់នូវព្រំដែននៃការស៊ើបសួរបឋមនោះទេ។ ក.ស.ច.ស. និង អង្គបុរេជំនុំជម្រះ បានសម្រេចថា ការស៊ើបសួរបឋមអាចមានការពិនិត្យឯកសារទាំងឡាយដែលមានជាសាធារណៈ[7] ការទាក់ទងជាមួយ "រដ្ឋមួយ (ឬ រដ្ឋច្រើន) ដើម្បី ... ធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងអត្ថិភាពនៃភស្តុតាងដែលមានប្រយោជន៍ចំពោះមេធាវីការពារក្តី ទោះបីមិនមែនជាភស្តុតាងដោះបន្ទុកក្តី [និង] ស្វែងរកច្បាប់ថតចម្លងនៃភស្តុតាងដែលបានលើកឡើង"[8] ឬ ការទាក់ទងជាមួយបុគ្គលណាម្នាក់ ដើម្បីបញ្ជាក់ថាតើគាត់មានឯកសារមួយចំនួនឬយ៉ាងណា[9]។

---

[6] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស លិខិតមកពី ក.ស.ច.ស. ផ្ញើជូនមេធាវីការពារក្តីរបស់ នួន ជា "កម្មវត្ថុ៖ ការឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៧ ពាក់ព័ន្ធនឹងការធ្វើកិច្ចស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ ឯកសារ A110/I ទំព័រ ២។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៥២ ជើងទំព័រ ១៤១។

[7] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងទុកឯកសាររួម ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D164/2 កថាខណ្ឌ ១៤។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ១២។

[8] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. ចំពោះសំណើសុំរបស់ លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេស ចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D315/1/5 កថាខណ្ឌ ១៥។

[9] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៥៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. សម្រេចលើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D273/3/5 កថាខណ្ឌ ២៩៖ "សហមេធាវីការពារក្តីជនត្រូវចោទ មិនបាន

វាសមហេតុផលក្នុងការសន្និតថា ការស៊ើបសួរបឋមមួយក៏អាចរួមមានការទាក់ទងជាមួយបុគ្គលទាំងឡាយផងដែរ ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅអំពីតំបន់ជាក់លាក់ណាមួយ។ សហចៅក្រមស៊ើបអង្កេតគួរតែបញ្ជាក់បំភ្លឺអំពីបញ្ហានេះ ដើម្បីឲ្យភាគីដឹងអំពីដែនកំណត់នៃការស៊ើបសួរបឋម។

៤. មេធាវីការពារក្តីយល់ឃើញថា ការទាក់ទងជាមួយបុគ្គលទាំងឡាយ ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅ ទាក់ទងនឹងតំបន់ដែលពាក់ព័ន្ធជាសក្តានុពលនៅក្នុងរឿងក្តី ០០៣ មិនចាត់ទុកថាជាការស៊ើបសួរឡើយ។ ការទាក់ទងបែបនេះ គឺគ្រាន់តែជាការស៊ើបសួរបឋម ដែលចាំបាច់សម្រាប់មេធាវីការពារក្តីក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៥(១០)។ មេធាវីការពារក្តីនឹងមិនធ្វើការស៊ើបសួរអង្គហេតុ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[10] ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ[11] ព្រោះថាតួនាទីនេះ គឺជាតួនាទីផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត[12]។ ការទាក់ទងជាមួយបុគ្គលទាំងឡាយ ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅ ទាក់ទងនឹងតំបន់ដែលពាក់ព័ន្ធជាសក្តានុពលនៅក្នុងរឿងក្តី ០០៣ គឺស្រដៀងគ្នាទៅនឹងការទាក់ទងជាមួយបុគ្គលទាំងឡាយ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន ប្រសិនបើពួកគេមានឯកសារពាក់ព័ន្ធ ដែលជាកិច្ចស៊ើបសួរបឋមដែលត្រូវបានអនុញ្ញាត[13]។ មេធាវីការពារក្តីនឹងផ្ទៀងផ្ទាត់ថា តើបុគ្គលទាំងនោះមានព័ត៌មានលម្អិតទូទៅ ដែលពាក់ព័ន្ធនឹងតំបន់មួយចំនួនឬយ៉ាងណា ហើយនឹងស្នើសុំព័ត៌មានទាំងនោះពីពួកគេ ។

៥. មេធាវីការពារក្តីស្នើសុំទាក់ទងជាមួយ [redacted] ដើម្បីសុំ [redacted] ឲ្យនាំផ្លូវមេធាវីការពារក្តី នៅក្នុងអំឡុងពេលនៃការចុះទស្សនកិច្ចសក្តានុភូតនៅ [redacted] ហើយសុំ [redacted] ឲ្យផ្តល់ព័ត៌មានលម្អិត

---

បង្ហាញថា ខ្លួនបានធ្វើកិច្ចស៊ើបសួរបឋមចំពោះបញ្ហាថា តើ [បុគ្គលដែលមិនបានបង្ហាញឈ្មោះ] អាច ឬ មិនអាចមានឯកសារទាំងអស់នេះទេ”។

[10] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[11] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D120។

[12] វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ចែងថា៖ “សហចៅក្រមស៊ើបអង្កេតត្រូវ ... ធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម”។

[13] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៥៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. សម្រេចលើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះទី ១០ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D273/3/5 កថាខណ្ឌ ២៩។

ទូទៅទាក់ទងនឹង[redacted]។ មេធាវីការពារក្តីនឹងមិនតាំងសំណួរបែបសារធាតុចំពោះ [redacted] ឡើយ ប៉ុន្តែគ្រាន់តែសុំឱ្យ[redacted]ពន្យល់ដោយឧទាហរណ៍អំពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ [redacted][14] ទាក់ទងនឹង[redacted]ប៉ុណ្ណោះ។ កិច្ចនេះ មិនមែនជាការស៊ើបសួរនោះទេ។ សហមេធាវីជាប់កាតព្វកិច្ចគោរពតាមក្រមសីលធម៌[15] ហើយយល់ដឹងថា ការតាំងសំណួរបែបសារធាតុដល់សាក្សីអាចនាំឱ្យមានការដាក់ទណ្ឌកម្ម អនុលោមតាមវិធាន ៣៥(ឃ) និង ៣៨។

---

[14] [redacted]

[15] វិធាន ២២(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃ ... ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់"។ មាត្រា ៦ នៃក្រមសីលធម៌នៃមេធាវី ដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចែងថា៖ "នៅគ្រប់កាលៈទេសៈ មេធាវីត្រូវតែគោរពកាតព្វកិច្ច ឬ ពាក្យសម្បថរបស់ខ្លួន និង ត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈនៃមនុស្សធម៌ និង នៃភាពគួរសមថ្លៃថ្នូរ។ មេធាវីមិនត្រូវចូលរួមនឹងសកម្មភាព ដែលមានលក្ខណៈផ្ទុយពីច្បាប់ និង បទបញ្ញា ផ្ទុយនឹងវិធានវិជ្ជាជីវៈ និង សម្បជញ្ញៈរបស់ខ្លួនដែលតម្រូវឱ្យធ្វើ"។ ដោយសារលោក Michael G. Karnavas គឺជាសមាជិកនៃគណៈមេធាវី Alaska វិធានវិជ្ជាជីវៈ Alaska ត្រូវបានអនុវត្ត។ *សូមមើល* បុព្វកថានៃវិធានវិជ្ជាជីវៈ Alaska (ចេញផ្សាយ ឆ្នាំ ២០១៥-២០១៦)៖ "ការប្រព្រឹត្តរបស់មេធាវី គួរតែអនុលោមតាមលក្ខខណ្ឌតម្រូវនៃច្បាប់"។

៦. មេធាវីការពារក្ដីត្រូវតែធ្វើការស៊ើបសួរបឋមបន្ថែមទៀត លើសពីការគ្រាន់តែការពិនិត្យមើលចម្លើយរបស់ [redacted] ដែលបានផ្ដល់ឲ្យ ក.ស.ច.ស.[16] និង សេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់[redacted]។ ការចុះទៅកាន់[redacted]ដោយផ្ទាល់ ជាមួយនឹង [redacted] នឹងអនុញ្ញាតឲ្យ[redacted]ពន្យល់ដោយឧទាហរណ៍អំពីចម្លើយមុនៗរបស់[redacted] ហើយនឹងផ្ដល់នូវព័ត៌មានបរិបទដល់មេធាវីការពារក្ដី។ ការណ៍នេះនឹងជួយមេធាវីការពារក្ដីឲ្យយល់ដឹងកាន់តែប្រសើរឡើងអំពីព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនៅទីតាំងនេះ។ ការណ៍ដែលអាចទាក់ទងជាមួយ [redacted] សម្រាប់គោលបំណងនេះ នឹងផ្ដល់អត្ថប្រយោជន៍ដល់មេធាវីការពារក្ដី នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការរៀបចំយ៉ាងយកចិត្តទុកដាក់នូវរឿងក្ដីរបស់លោក មាស មុត[17]។ មេធាវីការពារក្ដីក៏យល់ឃើញផងដែរថា ការធ្វើការស៊ើបសួរបឋម ដូចជាការប្រមូលសេចក្ដីពន្យល់ដោយផ្ទាល់ពី [redacted] ទាក់ទងនឹង[redacted] នៅក្នុងអំឡុងពេលនៃ[redacted] អាចលាតត្រដាងឲ្យឃើញនូវភ័ស្ដុតាងដោះបន្ទុកដែលអាចមាន។ បន្ទាប់មក មេធាវីការពារក្ដីនឹងអាចមានលទ្ធភាពដាក់សំណើសុំមួយទៅសហចៅក្រមស៊ើបអង្កេតឲ្យបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥ (១០)។

---

[16] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/46។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47។ កំណត់នៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49។

[17] *វចនានុក្រម* Black's Law កំណត់និយមន័យការយកចិត្តទុកដាក់ថាជា "ការយកចិត្តទុកដាក់ដែលអាចរំពឹងបានដោយសមហេតុផលពី និង អនុវត្តយ៉ាងសាមញ្ញដោយបុគ្គលដែលព្យាយាមបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ ឬ ក៏បំពេញកាតព្វកិច្ច"។ វចនានុក្រម Black's Law ៥២៣ (ចេញផ្សាយលើកទី ៩ ឆ្នាំ ២០០៩)។ វិធានក្រមសីលធម៌វិជ្ជាជីវៈ Alaska (ចេញផ្សាយ ឆ្នាំ ២០១៥-២០១៦) វិធាន ១.៣ ចែងថា៖ "មេធាវីត្រូវបំពេញកិច្ច ប្រកបដោយការយកចិត្តទុកដាក់សមស្រប និង ភាពឆាប់រហ័សនៅក្នុងការតំណាងក្ដីឲ្យកូនក្ដី"។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា* តទល់នឹង *Tadic* សំណុំរឿងលេខ IT-94-1 សាលដីកាលើញត្តិរបស់ម្ចាស់បណ្ដឹងស្នើសុំឲ្យពន្យាពេលកំណត់ និង ទទួលយកភ័ស្ដុតាងបន្ថែម ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៧៖ "ការយកចិត្តទុកដាក់ការពារក្ដី គឺជាគុណសម្បត្តិចាំបាច់របស់មេធាវីការពារក្ដី ដែលការពារជនជាប់ចោទនៅចំពោះមុខសាលាក្ដីអន្តរជាតិ...។ ដូចបានថ្លែងខាងលើ លក្ខខណ្ឌតម្រូវនៃការយកចិត្តទុកដាក់ការពារក្ដី រួមមានការប្រើប្រាស់ត្រឹមត្រូវនូវយន្តការនៃការការពារទាំងអស់ និង ការបង្ខិតបង្ខំ ដែលមាននៅក្នុងច្បាប់ និង វិធាននៃសាលាក្ដីអន្តរជាតិ ដើម្បីនាំយកភ័ស្ដុតាងក្នុងនាមជនជាប់ចោទ មកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។

## II. សេចក្តីសន្និដ្ឋាន និង ដំណោះស្រាយដែលស្នើសុំ

៧. មេធាវីការពារក្តីស្នើសុំទាក់ទងជាមួយបុគ្គលទាំងឡាយ ដូចជា សាក្សី ឬ សាក្សីសក្តានុភូត រួមទាំង [redacted] ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅ ទាក់ទងនឹងតំបន់ទាំងឡាយ ដែលពាក់ព័ន្ធជាសក្តានុពលនឹងរឿងក្តី ០០៣។ ក.ស.ច.ស. និង អង្គបុរេជំនុំជម្រះ មិនបានផ្តល់ការណែនាំណាមួយថា តើការបំពេញកិច្ចបែបនេះជាការស៊ើបសួរបឋមឬយ៉ាងណាឡើយ។ ការទាក់ទងជាមួយបុគ្គលទាំងឡាយ ក្នុងគោលបំណងនេះ ហាក់បីដូចជាការស៊ើបសួរបឋមដែលត្រូវបានអនុញ្ញាត ទោះបីជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែបញ្ជាក់បំភ្លឺលើបញ្ហានេះ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុដូចដែលបានជម្រាបជូនខាងលើ មេធាវីការពារក្តីគោរពស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតមេត្តា **បញ្ជាក់បំភ្លឺ** ថាតើមេធាវីការពារក្តីអាចទាក់ទងបុគ្គលទាំងឡាយ រួមទាំង [redacted] ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅបានឬយ៉ាងណា។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៣** ខែ**វិច្ឆិកា** ឆ្នាំ **២០១៥**
សហមេធាវីការពារក្តី លោក មាស មុត

| អាង ឧត្តម | Michael G. KARNAVAS |
|---|---|